# សិទ្ធិរបស់អ្នកក្រោមផ្នែកទី ៥០៤

*អ្នកមានសិទ្ធិទទួលព័ត៌មានពីស្រុកសាលាអំពីសិទ្ធិរបស់អ្នកក្រោមផ្នែកទី ៥០៤(Section 504)។ នេះជាសេចក្តីជូនដំណឹងពីសិទ្ធិរបស់អ្នកនិងកូនរបស់អ្នកក្រោមផ្នែកទី ៥០៤ និងសិទ្ធិដែលអ្នកមាន បើសិនអ្នកមិនយល់ស្របនឹងការសម្រេចរបស់ស្រុកសាលា។*

**តើអ្វីជាផ្នែកទី ៥០៤?**
ផ្នែកទី ៥០៤ នៃច្បាប់ស្តីពីការស្តារនីតិសម្បទានាឆ្នាំ ១៩៧៣ ដែលជាទូទៅហៅថា "ផ្នែកទី ៥០៤ (Section 504)" គឺជាច្បាប់សហព័ន្ធដែលការពារសិស្សពីការរើសអើងដោយពិការភាព។ ផ្នែកទី ៥០៤ ធានាថាសិស្សដែលមានពិការភាព មានឱកាសទទួលការអប់រំនិងអត្ថប្រយោជន៍ស្មើគ្នា ដូចដែលសិស្សមិនមានពិការភាពទទួលបានដែរ។ ដើម្បីទទួលបានសិទ្ធិនេះ សិស្សម្នាក់ត្រូវមានពិការភាពផ្នែកស្មារតី ឬរាងកាយណាមួយដែលដាក់កំហិតជាខ្លាំងដល់សកម្មភាពជីវិតសំខាន់ណាមួយ ឬច្រើន។

## ការសិក្សាអប់រំរបស់កូនអ្នក

កូនរបស់អ្នកមានសិទ្ធិ៖

- ទទួលការអប់រំសាធារណៈដែលសមរម្យដោយឥតគិតថ្លៃ។
- ចូលរួម និងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីអប់រំរបស់ស្រុកដោយគ្មានការរើសអើង។
- ទទួលបានឱកាសស្មើគ្នាក្នុងការចូលរួមសកម្មភាពក្រៅថ្នាក់រៀន និងមិនមែនសិក្សានានារបស់ស្រុក។
- ទទួលបានការអប់រំជាមួយសិស្សនានាដែលមិនមានពិការភាព ដល់កម្រិតអតិបរមាដែលសមស្រប។
- ទទួលបានការអប់រំក្នុងគ្រឹះស្ថានរួមទាំងបរិក្ខា និងទទួលបានសេវាកម្មនានាដែលប្រហាក់ប្រហែលគ្នានឹងអ្វីៗដែលផ្តល់ឲ្យសិស្សដែលមិនមានពិការភាពដែរ។
- ទទួលបានការស្នាក់នៅ និង/ឬជំនួយពាក់ព័ន្ធនានា និងសេវាកម្មផ្សេងៗដែលជួលឲ្យកូនរបស់អ្នកមានឱកាសស្មើគ្នាក្នុងការចូលរួមក្នុងសកម្មភាពនានារបស់សាលា។
- ទទួលបានជំនួយពាក់ព័ន្ធ និងសេវាកម្មនានាផ្នែកអប់រំដោយមិនបង់ថ្លៃ លើកលែងថ្លៃនានាដែលត្រូវបង់ដោយឪពុកម្តាយសិស្សដែលមិនមានពិការភាព។
- ទទួលបានសេវាអប់រំពិសេស ប្រសិនបើត្រូវការចាំបាច់។

## កំណត់ត្រាការសិក្សាអប់រំរបស់កូនអ្នក

អ្នកមានសិទ្ធិ៖

- ពិនិត្យមើលឡើងវិញនូវកំណត់ត្រានានាអំពីការអប់រំរបស់កូនអ្នក និងទទួលបានឯកសារចម្លងដោយមិនបង់ថ្លៃ។ អ្នកនឹងមិនត្រូវបានតម្រូវឲ្យបង់ប្រាក់ឡើយ ប្រសិនបើការចំណាយនោះអាចនឹងធ្វើឲ្យអ្នកមិនអាចពិនិត្យមើលឡើងវិញនូវកំណត់ត្រានានានោះ។
- ស្នើសុំស្រុកឲ្យប្តូរកំណត់ត្រាអំពីការអប់រំរបស់កូនអ្នក ប្រសិនបើអ្នកជឿថាកំណត់ត្រាទាំងនោះមិនត្រូវ ធ្វើឲ្យយល់ច្រឡំ ឬមិនដូចច្នោះ បំពានសិទ្ធិឯកជនភាពរបស់កូនអ្នក។ ប្រសិនស្រុកបដិសេធសំណើនេះ អ្នកមានសិទ្ធិតវ៉ាការបដិសេធន៍នោះ ដោយស្នើសុំសវនាការដែលអព្យាក្រឹត្យមួយ។
- ទទួលបានការឆ្លើយតបទៅនឹងសំណើសមស្របរបស់អ្នកឲ្យមានការពន្យល់ និងការបកស្រាយនានាអំពីកំណត់ត្រាការអប់រំរបស់កូនអ្នក។

## ដំណើរការផ្នែកទី ៥០៤

កូនរបស់អ្នកមានសិទ្ធិទទួលបានការវាយតម្លៃមុននឹងចូលសាលា ដើម្បីកំណត់ថាកូនរបស់អ្នកអាចទទួលបានសិទ្ធិស្ថិតក្រោមផ្នែកទី ៥០៤ ដែរឬទេ។ អ្នកមានសិទ្ធិ៖

- ទទួលបានការជូនដំណឹងមុននឹងស្រុកចាត់វិធានការណាមួយទាក់ទិននឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការដាក់ ចូលសាលាឲ្យកូនរបស់អ្នក។
- ឲ្យមានការវាយតម្លៃ និងសម្រេចដាក់ឲ្យចូលសាលាដោយក្រុមមនុស្សដែលជាញឹកញាប់ហៅថា "ក្រុម ៥០៤" រួមទាំងអ្នកទាំងឡាយណាដែលស្គាល់កូនរបស់អ្នក, ទទួលបានអត្ថន័យនៃព័ត៌មានអំពីការវាយតម្លៃ និងជម្រើសការដាក់ឲ្យចូលសាលា។
- ទទួលបានសេចក្តីសម្រេចវាយតម្លៃផ្អែកលើប្រភពផ្សេងៗគ្នា ដូចជាការធ្វើតេស្តសម្បទា និងសមិទ្ធិផល ការណែនាំគ្រូឲ្យលក្ខខណ្ឌរាងកាយ កំណត់ត្រាវេជ្ជសាស្ត្រ និងការអង្កេតរបស់ឪពុកម្តាយ។
- បដិសេធការអនុញ្ញាតចំពោះការវាយតម្លៃជាដំបូង និងការដាក់ឲ្យចូលសាលាជាដំបូងរបស់កូនអ្នក។

ប្រសិនបើកូនរបស់អ្នកមានសិទ្ធិស្ថិតក្រោមផ្នែកទី៥០៤ កូនរបស់អ្នកមានសិទ្ធិទទួលបានការវាយតម្លៃឡើងវិញតាមកាលកំណត់ រួមទាំងការវាយតម្លៃឡើងវិញមុនការផ្លាស់ប្តូរសំខាន់ណាមួយ ត្រូវបានធ្វើឡើងក្នុងការដាក់កូនរបស់អ្នកឲ្យចូលសាលា។

## ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ស្រុក

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់ស្រុកទាក់ទិននឹងកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការដាក់ចូលសាលាឲ្យកូនរបស់អ្នកក្រោមផ្នែកទី ៥០៤ អ្នកអាចស្នើសុំការសម្របសម្រួល ឬសវនាការតាមនីតិវិធីដោយអព្យាក្រឹត្យមួយ។ អ្នក និងកូនរបស់អ្នកមានសិទ្ធិចូលរួមក្នុងសវនាការ និងមានមេធាវីតំណាងឲ្យអ្នក។ ការស្នើសុំសវនាការ និងក្តីបារម្ភផ្សេងៗ អាចធ្វើឡើងទៅកាន់អ្នកសម្របសម្រួលផ្នែកទី ៥០៤ នៃស្រុករបស់អ្នក៖


Dave Peters
3900 Broadway
Everett, WA 98201
425-385-4063 | dpeters@everettsd.org


អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងអំពីការរើសអើងទៅការិយាល័យសិទ្ធិស៊ីវិល (OCR) របស់ក្រសួងអប់រំសហរដ្ឋអាមេរិក ឬដាក់ពាក្យបណ្តឹងទៅតុលាការសហព័ន្ធ។ ជាទូទៅ បណ្តឹង OCR មួយអាចត្រូវបានដាក់ក្នុងរយៈពេល ១៨០ថ្ងៃតាមប្រតិទិន គិតចាប់ថ្ងៃនៃចំណាត់ការដែលអ្នកជឿថាមានលក្ខណៈរើសអើង។ ការិយាល័យប្រចាំតំបន់មានទីតាំងស្ថិតនៅ 915 Second Ave, Room 3310, Seattle, WA 98174-1099 ។ លេខទូរស័ព្ទ : 206-607-1600/TDD: 206-607-1647 វេបសាយ : www.ed.gov/OCR ។